**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្តបន្ទាយមានជ័យ**

**លេខ:** ៣៩៧/ សខ.៧

# ជម្រាបមក

- លោក លោកស្រី អភិបាលនៃគណៈអភិបាល ក្រុង ស្រុក ទូទាំងខេត្ត
- លោក លោកស្រី ប្រធានមន្ទីរ អង្គភាព នានា ជុំវិញខេត្ត
- លោកនាយក បណ្តាអង្គការជាតិ អន្តរជាតិ ទូទាំងខេត្ត
- លោក លោកស្រី មេឃុំ ចៅសង្កាត់ ទូទាំងខេត្ត

**កម្មវត្ថុ:** កម្មវិធីសិក្ខាសាលាសមាហរណកម្មផែនការឃុំ-សង្កាត់ឆ្នាំ២០១៥ នៅថ្នាក់ក្រុង ស្រុក ទូទាំងខេត្ត ។

**យោង :** សេចក្តីណែនាំ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០០៤ ស្តីពីបច្ចេកទេសសម្រាប់ការរៀបចំដំណើរការសមាហរណកម្មផែនការ ឃុំ-សង្កាត់ នៅ ថ្នាក់ក្រុង ស្រុក របស់ក្រសួងផែនការ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប : លោក លោកស្រីប្រធានជ្រាបថា: ដើម្បីតម្រង់ទិសកម្មវិធីវិនិយោគគ្រប់បណ្តាថ្នាក់ គ្រប់បណ្តាវិស័យ គ្រប់បណ្តាអង្គការជាតិ-អន្តរជាតិ ឲ្យស៊ីសង្វាក់គ្នាជាមួយនឹងការរៀបចំកម្មវិធីវិនិយោគនៅថ្នាក់ឃុំ សង្កាត់ ទូទាំងខេត្តឆ្នាំ២០១៥ ព្រមទាំងធ្វើឲ្យកម្មវិធីវិនិយោគខេត្ត ក្រុង ស្រុក ឆ្នាំ២០១៥-២០១៧ ខាងមុខនេះមានលក្ខណៈឆ្លើយតបទៅនឹងតម្រូវការ និងគោលបំណងរបស់ឃុំ-សង្កាត់ទូទាំងខេត្ត គណៈអភិបាលខេត្ត ប្រគល់ភារកិច្ចជូន **មន្ទីរផែនការខេត្ត លោកនាយកទីចាត់ការផែនការនិងវិនិយោគសាលាខេត្ត លោក លោកស្រី អភិបាលនៃគណៈអភិបាលក្រុង ស្រុក** ចាត់ចែងសម្របសម្រួលរៀបចំសិក្ខាសាលាដ៏មានសារៈសំខាន់នេះ ក្នុងការគាំទ្រកិច្ចអភិវឌ្ឍន៍មូលដ្ឋានឆ្នាំ២០១៥ តាមបណ្តាក្រុង-ស្រុក ទូទាំងខេត្ត តាមកាលបរិច្ឆេទដូចខាងក្រោម :

| | | | | | |
|---|---|---|---|---|---|
| ១.ស្រុកម៉ាឡៃ | : | ថ្ងៃ ច័ន្ទ | ទី ១៥ | ខែ ធ្នូ | ឆ្នាំ២០១៤ |
| ២.ស្រុកអូរជ្រៅ | : | ថ្ងៃ អង្គារ៍ | ទី ១៦ | ខែ ធ្នូ | ឆ្នាំ២០១៤ |
| ៣.ក្រុងប៉ោយប៉ែត | : | ថ្ងៃ ពុធ | ទី ១៧ | ខែ ធ្នូ | ឆ្នាំ២០១៤ |
| ៤.ស្រុកភ្នំស្រុក | : | ថ្ងៃ ព្រហស្បតិ៍ | ទី ១៨ | ខែ ធ្នូ | ឆ្នាំ២០១៤ |

| | | | | | | |
|---|---|---|---|---|---|---|
| ៥.ស្រុកព្រះនេត្រព្រះ | : | ថ្ងៃ សុក្រ | ទី ១៩ | ខែ | ធ្នូ | ឆ្នាំ២០១៤ |
| ៦.ស្រុកថ្មពួក | : | ថ្ងៃ ច័ន្ទ | ទី ២២ | ខែ | ធ្នូ | ឆ្នាំ២០១៤ |
| ៧.ស្រុកស្វាយចេក | : | ថ្ងៃ អង្គារ៍ | ទី ២៣ | ខែ | ធ្នូ | ឆ្នាំ២០១៤ |
| ៨.ក្រុងសិរីសោភ័ណ | : | ថ្ងៃ ពុធ | ទី ២៤ | ខែ | ធ្នូ | ឆ្នាំ២០១៤ |
| ៩.ស្រុកមង្គលបូរី | : | ថ្ងៃ ព្រហស្បត៍ | ទី ២៥ | ខែ | ធ្នូ | ឆ្នាំ២០១៤ |

.ទីកន្លែងសិក្ខាសាលានៅគ្រប់សាលាក្រុង ស្រុក ។

.អ្នករៀបចំសិក្ខាសាលាដោយ រដ្ឋបាលគ្រប់ ក្រុង ស្រុក ។

.ដឹកនាំនិងសម្របសម្រួលដោយ រដ្ឋបាលគ្រប់ ក្រុង ស្រុក សហការគាំទ្រដោយមន្ទីរផែនការខេត្ត ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីប្រធាន លោកនាយក លោក លោកស្រី អភិបាលនៃគណៈអភិបាល ក្រុង ស្រុក ជ្រាបនិងរៀបចំចាត់ចែងចូលរួមគ្រប់សិក្ខាសាលាសមាហរណកម្មផែនការតាមបណ្ដាក្រុង ស្រុក តាមការគួរ ។

*សូមលោក លោកស្រី ទទួលនូវការរាប់អានអំពីខ្ញុំ*

បន្ទាយមានជ័យ ថ្ងៃទី២៤ ខែ១៣ ឆ្នាំ២០១៤

**អភិបាលខេត្ត**

គោ ស៊ុំ សារឿត

**ចម្លងជូន** :

-ក្រសួងមហាផ្ទៃ

-ក្រសួងផែនការ

-លេខាធិការដ្ឋាន គ.ជ.អ.ប

-ក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ

-ទីប្រឹក្សាកម្មវិធីជាតិថ្នាក់ខេត្ត

*(ដើម្បីជ្រាបជាព័ត៌មាន )*

-ឯកសារ-កាលប្បវត្តិ